ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ : ២៨១៨......ពណ.នចប

# សេចក្តីជូនដំណឹង
# ស្តីពី
# បែបបទ និងនីតិវិធីសំរាប់ការចុះបញ្ជីពាណិជ្ជកម្ម នៅមណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្ម ខេត្ត-ក្រុង

## ទីតាំង

ការិយាល័យនៃមណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្ម មានទីតាំងនៅក្នុងមន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង ឬនៅទីកន្លែងដទៃទៀតក្នុងរង្វង់ដែនដីខេត្តក្រុង អាស្រ័យដោយការកំណត់របស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

## ការចុះបញ្ជីនៅមណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មខេត្ត-ក្រុង

គ្រប់ក្រុមហ៊ុនសហកម្មសិទ្ធិ, ក្រុមហ៊ុនទទួលខុសត្រូវមានកំរិត, សហគ្រាសឯកបុគ្គល សាខា, ការិយាល័យ តំណាងក្រុមហ៊ុនដែលមានទីស្នាក់ការតាំងនៅរង្វង់ដែនដី អាចទទួលការចុះបញ្ជីដោយពេញលេញពីក្រសួងពាណិជ្ជកម្ម ដោយបង្ហាញពាក្យសុំចុះបញ្ជីនៅការិយាល័យ នៃមណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្ម ។

អ្នកសុំចុះបញ្ជីពាណិជ្ជកម្មអាចសំរេចចិត្តថា តើគេចង់ចុះឈ្មោះតាមទំរង់សហគ្រាសបែបណា ។

ជំរើសនៃទំរង់សហគ្រាសមានដូចខាងក្រោមនេះ

- សហគ្រាសឯកបុគ្គល
- សហគ្រាសសហកម្មសិទ្ធិ
- សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត
- ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត
- ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកំរិត
- សាខានៃក្រុមហ៊ុនបរទេស
- ការិយាល័យតំណាងនៃក្រុមហ៊ុនបរទេស
- សាខានៃក្រុមហ៊ុនខ្មែរ

ជាដំបូងសហគ្រាសទាំងអស់ ត្រូវទៅយកទំរង់បែបបទពាក្យសុំដែលត្រឹមត្រូវពីការិយាល័យនៃមណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្ម ដែលនៅទីនោះ គេនឹងផ្តល់ពត៌មានពីបែបបទនៃការចុះបញ្ជីសហគ្រាស ។

**ការរំញែកចេញសហគ្រាសធុនតូច**

សហគ្រាសធុនតូចដែលប្រតិបត្តិការមិនស្ថិតនៅក្នុងរបបពិត (យោង: ប្រកាសលេខ ៧៩៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីចំនូនកំណត់) ប៉ុន្តែនៅក្នុងរបបមៅការ (យោង: សេចក្តីណែនាំលេខ 006 SCN.SHV.PD ចុះថ្ងៃទី ២០ មិនា ២០០៧) ត្រូវការសុំលិខិតអនុញ្ញាតនៅមន្ទីរពាណិជ្ជកម្មខេត្ត ឬច្រកចេញចូលតែមួយ (មិនត្រូវការចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម) ប្រសិនបើអាជីវកម្មរបស់គេស្ថិតនៅក្នុងរង្វង់ខេត្ត-ក្រុង ។

**បែបបទនៃការត្រួតពិនិត្យឈ្មោះ**

សហគ្រាសទាំអស់ដែលមកសុំចុះបញ្ជីពាណិជ្ជកម្មត្រូវធ្វើការពិនិត្យដើម្បីអោយប្រាកដថា ឈ្មោះដែលគេជ្រើសរើស មិនមានប្រើ ឬមិនស្រដៀងគ្នានឹងឈ្មោះដែលមានចុះក្នុងបញ្ជីពាណិជ្ជកម្មរួចហើយ ឬ មិនមានក្នុងបញ្ជីឈ្មោះបំរុងដែលគេរក្សាទុក ។

ការពិនិត្យឈ្មោះអាចប្រព្រឹត្តទៅតាមទូរស័ព្ទ ឬ បញ្ជូនសារពីការិយាល័យនៃមណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្ម ទៅការិយាល័យចុះបញ្ជីពាណិជ្ជកម្ម នៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម ។

ការពិនិត្យចុងក្រោយនឹងប្រព្រឹត្តទៅនៅពេលដែលឯកសារដើមទាំងអស់ បានមកដល់ការិយាល័យចុះបញ្ជីពាណិជ្ជកម្ម នៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម ។

**ទំរង់ពាក្យសុំ និង គំរូផ្សេងៗ**

បន្ទាប់ពីការពិនិត្យឈ្មោះ សហគ្រាសត្រូវបានគេប្រគល់អោយនូវទំរង់ពាក្យសុំសំរាប់ប្រភេទសហគ្រាសនោះ ។ ទំរង់ពាក្យសុំត្រូវតែដូចគ្នានឹងទំរង់ដែលបានប្រើនៅការិយាល័យចុះបញ្ជីពាណិជ្ជកម្ម នៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៅក្រសួងពាណិជ្ជកម្ម ។

ក្នុងករណីនៃការសុំរបស់ក្រុមហ៊ុនទទួលខុសត្រូវមានកំរិត មន្ត្រីនៃការិយាល័យមណ្ឌលសាខាចុះបញ្ជីនឹងផ្តល់អោយសហគ្រាស នូវគំរូលក្ខន្តិកៈពាណិជ្ជកម្មជាច្បាប់ថតចំលង ឬអេឡិចត្រូនិច (តាមពត៌មានអ្នកសុំ) ហើយពន្យល់ពីបែបបទទាក់ទិននឹងឯកសារនេះផង ។

**បែបបទឯកសារសំរាប់ការចុះបញ្ជីពាណិជ្ជកម្ម**

សំរាប់ក្រុមហ៊ុនទទួលខុសត្រូវមានកំរិត បែបបទនៃការចុះបញ្ជីត្រូវស្ថិតក្នុងរង្វង់ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម, ច្បាប់វិសោធនកម្មនៃច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម, ច្បាប់សហគ្រាសពាណិជ្ជកម្ម ប្រកាសអន្តរក្រសួងលេខ ៦៧៩ សហវ.ប្រក.ចមព ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ២០០៧ ស្តីពីកំរៃ

រដ្ឋបាលក្នុងការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងសេចក្ដីជូនដំណឹងលេខ ១៤១៤ MOC/SM 2006 ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៦ ស្ដីពីឯកសារតំរូវការសំរាប់ការចុះបញ្ជីពាណិជ្ជកម្ម ។

សហគ្រាសត្រូវយកឯកសារទាក់ទិនទាំងអស់ជូនទៅការិយាល័យនៃមណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្ម។

អនុលោមតាមមាត្រា ២៥ នៃច្បាប់ស្ដីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម, ច្បាប់វិសោធនកម្ម នៃច្បាប់ស្ដីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម, ប្រសិនបើឯកសារមិនគ្រប់គ្រាន់ទេ សហគ្រាសនឹងត្រូវបាន ទុកពេលអោយដប់ប្រាំ (១៥) ថ្ងៃ ដើម្បីកែតំរូវ និងបំពេញបន្ថែម ហើយបញ្ជូនឯកសារមកវិញអោយបាន គ្រប់គ្រាន់ ។

មន្ត្រីចុះបញ្ជីត្រួតពិនិត្យមើលលក្ខន្តិកៈរបស់ក្រុមហ៊ុន និងសំណុំលិខិតស្នើសុំ ហើយនៅពេលយល់ឃើញថា ឯកសារគ្រប់គ្រាន់ ត្រូវអញ្ជើញអ្នកស្នើសុំអោយទៅការិយាល័យនាយក ដើម្បីបង់កំរៃរដ្ឋបាលចុះបញ្ជី តាមតម្លៃត្រឹមត្រូវ ។

## កំរៃរដ្ឋបាលក្នុងការចុះបញ្ជីពាណិជ្ជកម្ម

នៅពេលបង់ប្រាក់ ឈ្មោះអ្នកស្នើសុំចុះបញ្ជីនិងកំណត់ត្រានៃការបង់លុយរបស់គេត្រូវកត់បញ្ចូលទៅក្នុងសៀវភៅបង់លុយ ហើយមន្ត្រីចុះបញ្ជីត្រូវប្រាប់ទៅអ្នកស្នើសុំពីពេលដែលត្រូវត្រឡប់មកយកវិញ្ញាបនប័ត្រចុះបញ្ជី និងលិខិតអនុញ្ញាត ។

អ្នកសុំត្រូវទទួលបង្កាន់ដៃសំរាប់ការបង់ប្រាក់របស់គេ ទុកជាភ័ស្តុតាងថាគេបានបង់កំរៃរដ្ឋបាលចំពោះការ ចុះបញ្ជីគ្រប់ចំនួនហើយ ។

សហគ្រាសត្រូវបង់កំរៃចុះបញ្ជី ស្របតាមប្រកាសអន្តរក្រសួង លេខ ៦៧៥ សហវ.ប្រក.ចមព ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៧ ។

កំរៃរដ្ឋបាលក្នុងការចុះបញ្ជីដែលបានប្រមូលនៃមណ្ឌលសាខាចុះបញ្ជី ត្រូវបញ្ជូនមកនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ដើម្បីបង់ចូលថវិការដ្ឋ ។

## ហត្ថលេខានៃការទទួលសំរាប់ទុកជាឯកសារ

ជាបន្ថែមទៀតអ្នកស្នើសុំត្រូវចុះហត្ថលេខាទទួល សំរាប់ផ្នែកទុកដាក់ឯកសារនៃទំរង់ពាក្យសុំ។ ប្រសិនបើអ្នកស្នើសុំជាអ្នកសម្របសំរួលសំរាប់សហគ្រាស នាយក ឬម្ចាស់ភាគហ៊ុន (សំរាប់ក្រុមហ៊ុន) ឬសហកម្មសិទ្ធិករទូទៅ (សំរាប់សហកម្មសិទ្ធិ) ឬអ្នកគ្រប់គ្រង (ប្រសិនបើជាការិយាល័យតំណាង ឬសាខា) ត្រូវមកកាន់ការិយាល័យនៃមណ្ឌលសាខាចុះបញ្ជីមួយ (១) ថ្ងៃ ក្រោយពីបានបង់កំរៃរដ្ឋបាលចុះបញ្ជី និងប្រគល់ឯកសារទាំងអស់រួចហើយ ។

បង្កាន់ដៃសំរាប់ការទុកឯកសារត្រូវបានចុះហត្ថលេខាអមដោយប្រធានការិយាល័យនៃមណ្ឌលសាខាចុះបញ្ជី ។ បន្ទាប់មកបេឡាកររបស់នាយកបោះត្រា, ចុះហត្ថលេខា, ចុះថ្ងៃខែ ហើយបញ្ជូនចូលទៅក្នុងថវិការដ្ឋ ។

## ការដាក់លេខចុះបញ្ជីពាណិជ្ជកម្ម និងលេខកាលប្បវត្តិ

សំណុំឯកសារពេញលេញត្រូវបានបញ្ជូនទៅមន្ត្រីចុះបញ្ជីដើម្បីបញ្ចប់ការត្រួតពិនិត្យ ។ នៅពេលពិនិត្យរួចហើយ មន្ត្រីចុះបញ្ជីកំណត់លេខកាលប្បវត្តិ និង អត្តលេខចុះបញ្ជីដោយដៃ។ ការធ្វើនេះប្រព្រឹត្តទៅដោយទំនាក់ទំនងតាមទូរស័ព្ទ ឬអ៊ីម៉ែលជាមួយនឹងការិយាល័យចុះបញ្ជី នៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម។ លេខទាំងនេះចេញដោយមន្ត្រី នៅកន្លែងចុះបញ្ជីនៅការិយាល័យចុះបញ្ជីពាណិជ្ជកម្ម នៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៅក្រសួងពាណិជ្ជកម្ម ហើយសរសេរលើសៀវភៅដែលរក្សាទុកនៅការិយាល័យនេះ។ លេខកាលប្បវត្តិគ្រាន់តែលេខរៀងបន្តក្នុងសៀវភៅ ហើយអត្តលេខចុះបញ្ជីក្រុមហ៊ុនបន្តលេខរៀង ប្រើតាមប្រភេទនៃសហគ្រាស។

## លេខកាលប្បវត្តិនៃការចុះឈ្មោះ

លេខនេះមានទំរង់ XXX/YY. ដែល XXX ជាលេខរៀងនៃការចុះឈ្មោះក្នុងឆ្នាំ។ លេខ YY សំគាល់ឆ្នាំ ឧទាហរណ៍ ០៧ តាងអោយឆ្នាំ ២០០៧។

## អត្តលេខចុះបញ្ជីឈ្មោះពាណិជ្ជកម្ម

លេខនេះមានទំរង់ WWWW/ZZQ. ដែល WWWW ជាលេខរៀងដែលតាងអោយលេខនៃប្រភេទនៃកាចុះឈ្មោះក្នុងឆ្នាំ។ លេខនេះសំរាប់ក្រុមហ៊ុនទទួលខុសត្រូវមានកំរិត (ទាំងក្រុមហ៊ុនឯកជន និងសាធារណៈទទួលខុសត្រូវមានកំរិត), មានលេខរៀងមួយ សំរាប់ការិយាល័យតំណាង ឬសាខាក្រុមហ៊ុន, មានលេខមួយទៀតសំរាប់សហគ្រាស ឯកបុគ្គល។ ចំពោះផ្នែក ZZQ វិញ, ZZ មាន លេខ ២ខ្ទង់តាងអោយឆ្នាំដូចជា ០៧ តាងអោយឆ្នាំ ២០០៧ ហើយផ្នែក Q វិញគឺជាលេខសំគាល់កូដការិយាល័យចុះបញ្ជីពាណិជ្ជកម្ម តែមួយក្នុងចំណោមខាងក្រោមនេះ :

| ប្រភេទ (ដូចផ្នែក ៤ នៃពាក្យសុំ) | កូដដែលប្រើក្នុងលេខចុះបញ្ជីសហគ្រាស |
|---|---|
| សហកម្មសិទ្ធិទូទៅ | P= សញ្ជាតិខ្មែរ<br>E= សញ្ជាតិបរទេស |
| ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត | |
| សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត | |
| ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកំរិត | |
| សហគ្រាសឯកបុគ្គល | I= សញ្ជាតិខ្មែរ<br>IE= សញ្ជាតិបរទេស |
| សាខា / ការិយាល័យតំណាង | B |

### លិខិតអនុញ្ញាតចុះបញ្ជីពាណិជ្ជកម្មបណ្តោះអាសន្ន

នៅពេលដែលលេខកាលប្បវត្តិ និងអត្តលេខចុះបញ្ជីពាណិជ្ជកម្ម បានចេញនិងសរសេរលើឯកសារពាក្យសុំហើយ. មន្ត្រីចុះបញ្ជី ត្រូវបញ្ចូលពត៌មានរបស់សហគ្រាសដែលបានផ្តល់នៅលើឯកសារពាក្យសុំទៅក្នុង MS Excel macro ដែលអាចចេញលិខិតអនុញ្ញាតចុះបញ្ជីពាណិជ្ជកម្មបណ្តោះអាសន្ន ជាទ្រង់ទ្រាយអាចបោះពុម្ពបាន ដែលចែងពីចំណុចសំខាន់ៗរបស់ពាក្យសុំ សំរាប់ការចុះបញ្ជីក្រុមហ៊ុន។ ពង្រាងលិខិតអនុញ្ញាតចុះបញ្ជីពាណិជ្ជកម្មបណ្តោះអាសន្ននេះ ត្រូវបញ្ជូនជាមួយនឹងឯកសារច្បាប់ដើមផ្សេងៗមកនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ហើយថែមទាំងបញ្ជូនតាមរយៈអ៊ីម៉ែលទៅការិយាល័យចុះបញ្ជីពាណិជ្ជកម្ម នៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម។

### ការឯកភាពយល់ព្រមដោយប្រធានមន្ទីរពាណិជ្ជកម្មខេត្ត

លិខិតអនុញ្ញាតចុះបញ្ជីពាណិជ្ជកម្មបណ្តោះអាសន្ន មានសុពលភាពមួយខែ និង ត្រូវបានចុះហត្ថលេខានិងប្រថាប់ត្រាដោយប្រធានមន្ទីរពាណិជ្ជកម្មខេត្ត មុននឹងឯកសារត្រូវបញ្ជូនទៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៅក្រសួងពាណិជ្ជកម្ម។

### ការបញ្ជូនឯកសារ និង កំរៃរដ្ឋបាលទៅក្រសួងពាណិជ្ជកម្ម

មធ្យោបាយដែលធ្វើការបញ្ជូនឯកសារ និងកំរៃរដ្ឋបាលចុះបញ្ជីទៅកាន់ការិយាល័យចុះបញ្ជីពាណិជ្ជកម្ម នៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នឹងអាចតាមលទ្ធភាពផ្សេងៗគ្នានៃការដឹកជញ្ជូន ឬតាមមន្ត្រីចុះបញ្ជីដែលធ្វើដំណើរមកភ្នំពេញ ។ ការបញ្ជូនពត៌មានពីមណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មទៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម អាចធ្វើទៅបានតាមរយៈបណ្តាញ Internet ដូចជា Scan ឯកសារ និងផ្ញើ E-mail ។

ឯកសារទាំងអស់ ត្រូវផ្ញើទៅកាន់នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ។

### វិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្ម និងលិខិតអនុញ្ញាតចុះបញ្ជីពាណិជ្ជកម្ម

វិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្មជាមួយនឹងលិខិតអនុញ្ញាតចុះបញ្ជីពាណិជ្ជកម្ម ពីក្រសួងពាណិជ្ជកម្ម ត្រូវតែប្រមូល ហើយបញ្ជូនតាមលទ្ធភាពផ្សេងៗគ្នានៃការដឹកជញ្ជូន ឬតាមមន្ត្រីចុះពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ទៅកាន់មន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង ។

### ការជូនដំណឹងទៅសហគ្រាស

សហគ្រាសអាចត្រឡប់មកយកវិញតាមកាលបរិច្ឆេទដែលបានព្រមព្រៀង ឬអាចជាជំរើសមួយទៀតតាមទូរស័ព្ទ ពីការអាចមកយកវិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្មនិងលិខិតអនុញ្ញាតចុះបញ្ជីពាណិជ្ជកម្មបាន។

### ប្រតិបត្តិការឯទៀតនៅការិយាល័យនៃមណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្ម

ការចុះឈ្មោះបន្ទាប់ទៀត ជាទូទៅដែលធ្លាប់តែធ្វើនៅការិយាល័យចុះឈ្មោះពាណិជ្ជកម្មនៅភ្នំពេញ, ក៏អាចធ្វើនៅការិយាល័យនៃមណ្ឌលសាខាចុះបញ្ជីខេត្ត-ក្រុងបានដែរ ។ និតិវិធីមានចែងដូចខាងក្រោមនេះ :

**វិសោធនកម្មលើលក្ខន្តិកៈក្រុមហ៊ុន**

នៅពេលដែលក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត ត្រូវការធ្វើវិសោធនកម្មលើលក្ខន្តិកៈពាណិជ្ជកម្មរបស់គេ ក្រុមហ៊ុននោះ ត្រូវទៅការិយាល័យ នៃមណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្ម ដាក់ឯកសារដែលត្រូវ ហើយបង់កំរៃរដ្ឋបាលក្នុងការចុះបញ្ជីពាណិជ្ជកម្ម តាមការកំណត់ដូចចែងក្នុងប្រកាសអន្តរក្រសួងលេខ ៦៧៩ សហវ.ប្រក.ធមព ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៧ ។

**ការរំលាយសហគ្រាស**

នៅពេលដែលសហគ្រាសចង់លុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម គេត្រូវទៅការិយាល័យ នៃមណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្ម ហើយដាក់ពាក្យសុំលុបឈ្មោះសហគ្រាសចេញពីបញ្ជីពាណិជ្ជកម្ម ។ គេត្រូវប្រើឯកសារទំរង់ គ ។

**ប្រតិវេទន៍ប្រចាំឆ្នាំនៃក្រុមហ៊ុន**

ទំរង់ប្រើប្រាស់នៃប្រតិវេទន៍ប្រចាំឆ្នាំសំរាប់សហគ្រាសពាណិជ្ជកម្ម ដូចគ្នានឹងទំរង់ប្រតិវេទន៍ដែលប្រើប្រាស់ នៅការិយាល័យប្រតិវេទន៍ នៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ។

អនុលោមតាមប្រកាសរបស់ក្រសួងពាណិជ្ជកម្ម លេខ ១៤៩ ចុះថ្ងៃទី ៥ កក្កដា ២០០៦ ក្រុមហ៊ុនទាំងអស់ ដែលបានចុះ ឈ្មោះជាមួយក្រសួងពាណិជ្ជកម្មត្រូវធ្វើប្រតិវេទន៍ប្រចាំឆ្នាំ។

ប្រតិវេទន៍ប្រចាំឆ្នាំនេះ ត្រូវដាក់ជូនការិយាល័យ នៃមណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្ម ឬការិយាល័យប្រតិវេទន៍ នៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៅក្រសួងពាណិជ្ជកម្ម។

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៧

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

ចម ប្រសិទ្ធ

**ចម្លងជូន :**

-ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ហោ ណាំហុង**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងមហាផ្ទៃ
-សាលាខេត្ត-ក្រុង
-មន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង
-ដូចប្រការ ១០ "ដើម្បីអនុវត្ត"
-ADB TA 4786-CAM
-អគ្គនាយកដ្ឋានរាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធ**
នៃ
បែបបទ និង នីតិវិធីសំរាប់ការ
ចុះបញ្ជីពាណិជ្ជកម្មនៅមណ្ឌល
សាខាខេត្ត-ក្រុង

## បែបបទទំនាក់ទំនង
## ចុះបញ្ជីពាណិជ្ជកម្ម នៅសាខា
## ចុះបញ្ជីពាណិជ្ជកម្ម មណ្ឌលខេត្ត-ក្រុង

